# សេចក្តីថ្លែងការណ៍រួម

## រវាងឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន និងឯកឧត្តម David Scheffer

## អ្នកជំនាញពិសេសរបស់អគ្គលេខាធិការ អ.ស.ប.

នៅរសៀលថ្ងៃនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន បានជួបជាមួយឯកឧត្តមឯកអគ្គរដ្ឋទូត ដាវីដ សែហ្វឺ (David Scheffer) អ្នកជំនាញពិសេសរបស់លោកអគ្គលេខាធិការ អ.ស.ប.សម្រាប់ជំនួយរបស់អង្គការសហប្រជាជាតិសម្រាប់ការកាត់ទោសខ្មែរក្រហមដើម្បីពិភាក្សាលើកិច្ចសហប្រតិបត្តិការដែលកំពុងដំណើរការរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិដើម្បីគាំទ្រអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។

កិច្ចប្រជុំពិភាក្សារវាងភាគីទាំងពីរបានប្រព្រឹត្តទៅ នៅក្នុងបរិយាកាសស្និទ្ធស្នាល និងយោគយល់គ្នា ហើយផ្តោតសំខាន់ទៅលើបញ្ហាសំខាន់ៗមួយចំនួន ដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកំពុងប្រឈម។ ភាគីទាំងពីរ បានយល់ស្របថា ដំណើរការជំនុំជម្រះក្តីនៅតុលាការខ្មែរក្រហម គឺជាសមិទ្ធផលជាប្រវត្តិសាស្ត្រ ដើម្បីបម្រើផលប្រយោជន៍យុត្តិធម៌ និងជនរងគ្រោះ។

បើទោះបីជាឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន និងអ្នកជំនាញពិសេស មានការយល់ឃើញ ផ្សេងគ្នាពីការបកស្រាយលើកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក.យ៉ាងណាក៏ដោយ ភាគីទាំងពីរមានឆន្ទៈបន្តកិច្ចពិភាក្សាដ៏ជិតស្និទ្ធជុំវិញបញ្ហាដ៏សំខាន់ៗទាំងឡាយ ហើយភាគីទាំងពីរនៅតែមានសុទិដ្ឋិនិយមថា អង្គជំនុំជម្រះនេះនឹងអាចទទួលបានជោគជ័យក្នុងអាណត្តិរបស់ខ្លួន។

**ភ្នំពេញ ថ្ងៃទី ២៤ ខែមករា ឆ្នាំ ២០១២**